ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី
រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
លេខ : 1105 អស.

# ប្រកាស

## ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ
## របស់អគ្គាធិការដ្ឋានមុខងារសាធារណៈ

### រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស រកត១១ ៩៨ -៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម លេខ ០២ នស ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ២០នស. រ កម ០១៩៦- ២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យ លេខ ២០អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យ លេខ១៩ អនក្រ-បកចុះថ្ងៃទី ២៨ខែ ឧសភា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមតំរូវការចាំបាច់ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

# សំរេច

**ប្រការ១:** អគ្គាធិការដ្ឋាន ជាសេនាធិការសំខាន់របស់ថ្នាក់ដឹកនាំ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ មានមុខងារ និងភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវ រៀបចំផែនការអធិការកិច្ច ប្រចាំឆ្នាំក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ដើម្បីសុំការសំរេចពីប្រធានស្ថាប័ន។
- ធ្វើអធិការកិច្ចក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង ខេត្ត ក្រុង ក្នុងវិស័យមុខងារសាធារណៈ និងរាយការណ៍ជូនរដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។
- សហការសិក្សាស្រាវជ្រាវ រាល់ពាក្យបណ្តឹង តវ៉ា បរិហារ របស់មន្ត្រីរាជការស៊ីវិល។
- គ្រប់របាយការណ៍ នៃការធ្វើ អធិការកិច្ចត្រូវរក្សាការសម្ងាត់ដាច់ខាត ប្រធានស្ថាប័នជាអ្នកសំរេចចំពោះការផ្សព្វផ្សាយនូវរបាយការណ៍អធិការកិច្ចទាំងនោះ ។
- ប្រតិបត្តិការភារកិច្ចតាមបញ្ជា របស់រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

**ប្រការ២:** អគ្គាធិការដ្ឋានមានការិយាល័យអធិការកិច្ចចំណុះចំនួន ៣ ÷

១ - ការិយាល័យអធិការកិច្ចរដ្ឋបាល និង សរុប

២ - ការិយាល័យអធិការកិច្ចមុខងារសាធារណៈ

៣ - ការិយាល័យអធិការកិច្ច គណនេយ្យ និង ហិរញ្ញវត្ថុ

ការិយាល័យនីមួយៗត្រូវបែងចែកមុខការដោយកំណត់ផ្ទៃក្នុង ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

**ប្រការ៣:** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹង ប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤:** អគ្គនាយកនៃ អគ្គនាយកដ្ឋានមុខងារសាធារណៈ អគ្គាធិការ នៃអគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធ មានភារកិច្ចអនុវត្តន៍ប្រកាសនេះអោយបានល្អចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០២

**រដ្ឋលេខាធិការ**

**ម្លងជូន :**

ទីស្តីការគណៈរដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

"ដើម្បីជូនជ្រាប"

ដូចប្រការ ៤

ឯកសារ-កាលប្បវត្តិ